ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១៥៤ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៧

## ប្រកាស

## ស្តីពី

## ការដាក់ឲ្យប្រើប្រាស់ឯកសារស្តីពីយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## និងជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញសេចក្តីសម្រេចលេខ ៨៨ សសរ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍របស់រាជរដ្ឋាភិបាល
- យោងតាមសំណើរបស់ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងដាក់ឲ្យប្រើប្រាស់យន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន ដូចមានឯកសារស្តីពីយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន ជាឧបសម្ព័ន្ធ។

**ប្រការ២.-**

យន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន មានគោលដៅដើម្បី៖

- ធានាគុណភាពនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដល់សិស្ស-និស្សិតតាមស្ថាប័ន ឬកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ស្របតាមប្រព័ន្ធគុណវុឌ្ឍិជាតិ និងអាស៊ាន។
- ធ្វើការវាយតម្លៃសមត្ថភាព និងគុណវុឌ្ឍិអ្នកជំនាញដែលកំពុងបម្រើការងារក្នុងវិស័យទេសចរណ៍ ដើម្បីទទួលបានការទទួលស្គាល់ក្នុងកម្រិតវិញ្ញាបនបត្រ ឬសញ្ញាបត្រវិជ្ជាជីវៈទេសចរណ៍ជាក់លាក់ ស្របតាមប្រព័ន្ធគុណវុឌ្ឍិជាតិ និងអាស៊ាន ព្រមទាំងផ្តល់លទ្ធភាពឱ្យអ្នកជំនាញទេសចរណ៍អភិវឌ្ឍជំនាញកាន់តែខ្ពស់ក្នុងអាជីពរបស់ខ្លួន។
- លើកកម្ពស់គុណតម្លៃជំនាញវិជ្ជាជីវៈទេសចរណ៍តាមរយៈ ការផ្តល់នូវការទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ដែលធានាដល់ការរក្សា និងបង្កើនមូលធនមនុស្សឱ្យស្ថិតនៅក្នុងវិស័យទេសចរណ៍ តាមរយៈការផ្តល់ច្រកសិក្សា និងច្រកវាយតម្លៃច្បាស់លាស់សម្រាប់សិស្ស-និស្សិត និងអ្នកកំពុងបម្រើការងារ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ (រួមមាន សាលាវិជ្ជាជីវៈទេសចរណ៍ គ្រឹះស្ថានសិក្សាទេសចរណ៍ និងបដិសណ្ឋារកិច្ច កម្មវិធីបណ្តុះបណ្តាលជំនាញទេសចរណ៍) សិស្សានុសិស្ស សិក្ខាកាម អ្នកកំពុងបម្រើការងារក្នុងវិស័យទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃអ្នកជំនាញទេសចរណ៍ និងការវាយតម្លៃអ្នកជំនាញទេសចរណ៍នៅកម្ពុជា ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN MRA-TP)។

**ប្រការ៤.-**

បច្ចេកសព្ទប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ៖

**ការវាយតម្លៃ៖** ជាដំណើរការនៃការប្រមូលភស្តុតាង ដើម្បីបញ្ជាក់ថា អ្នកសិក្សា ឬអ្នកជំនាញមានសមត្ថភាពស្របតាមស្តង់ដាដែលបានកំណត់។ ការវាយតម្លៃក៏ត្រូវបានប្រើជាផ្នែកនៃដំណើរការសិក្សាដើម្បីជួយដល់អ្នកសិក្សាក្នុងការធ្វើឱ្យមានការរីកចម្រើនផ្នែកចំណេះដឹង ជំនាញ និងអត្តចរិត។

គុណវុឌ្ឍិ ជា៖

១. បណ្ណុំនៃសមត្ថភាពដែលឆ្លើយតបទៅនឹងតួនាទីការងារ និងផ្នែកសំខាន់នៅកន្លែងធ្វើការ។

២. វិញ្ញាបនបត្រ សញ្ញាបត្រ ឬកម្រិតដែលផ្តល់ដោយគ្រឹះស្ថានផ្តល់ការអប់រំ ឬក្រុមដែលមានសិទ្ធិផ្តល់គុណវុឌ្ឍិ និងបញ្ជាក់ពីការទទួលបានលទ្ធផលសិក្សា។

៣ ការបញ្ជាក់ផ្លូវការ ដែលចេញដោយអង្គភាពពាក់ព័ន្ធ ក្នុងការទទួលស្គាល់ថាបុគ្គលម្នាក់សម្រេចបានលទ្ធផលសិក្សា ឬទាក់ទងទៅនឹងតម្រូវការរបស់បុគ្គល អាជីព ក្រុមហ៊ុន ឬសហគមន៍។

**សាលាវិជ្ជាជីវៈទេសចរណ៍៖** សំដៅដល់គ្រឹះស្ថានសិក្សាដែលបង្កើតឡើងដោយផ្នែកសាធារណៈ ផ្នែកឯកជន ចម្រុះរដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានការអប់រំបណ្តុះបណ្តាលអ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចសំដៅបម្រើឲ្យឧស្សាហកម្មទេសចរណ៍។

**គ្រឹះស្ថានសិក្សាទេសចរណ៍ និងបដិសណ្ឋារកិច្ច៖** សំដៅដល់គ្រឹះស្ថានសិក្សាជាសាកលវិទ្យាល័យ មហាវិទ្យាល័យ វិទ្យាស្ថានដែលបង្កើតឡើងដោយផ្នែកសាធារណៈ ផ្នែកឯកជន ចម្រុះរដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋាកិច្ច។

**កម្មវិធីបណ្តុះបណ្តាលជំនាញទេសចរណ៍៖** សំដៅដល់ការបណ្តុះបណ្តាលរយៈខ្លី មធ្យម ឬវែង ផ្តល់ដោយអង្គការជាតិ ឬអន្តរជាតិ សមាគមទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ ឬអ្នកជំនាញដែលមានការទទួលស្គាល់។

**ការធានាគុណភាព៖** សំដៅដល់គ្រប់សកម្មភាពដែលផ្តល់ការធានាថា សេវានៃការអប់រំ និងបណ្តុះបណ្តាលរបស់គ្រឹះស្ថាន ឬអង្គភាពបណ្តុះបណ្តាលត្រូវបានផ្តល់ប្រកបដោយប្រសិទ្ធភាពជាប់ជានិច្ចទៅតាមតម្រូវការស្តង់ដា និងស្របតាមគោលដៅ និងគោលបំណងដែលបានផ្សព្វផ្សាយ។

**ច្រកសិក្សា៖** ច្រកអាចបត់បែនបានដែលបង្កលក្ខណៈងាយស្រួលដល់អ្នកសិក្សា ឬអ្នកកំពុងធ្វើការក្នុងការផ្លាស់ប្តូរទៅវិញទៅមករវាងវិស័យអប់រំចំណេះដឹងទូទៅ និងឧត្តមសិក្សាជាមួយវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងការសិក្សាគុណវុឌ្ឍិកម្រិតខ្ពស់បន្ថែមទៀត តាមរយៈការទទួលស្គាល់ការសិក្សាពីមុន រួមមានការផ្ទេរក្រេឌីត ព្រមទាំងការទទួលស្គាល់បទពិសោធន៍ និងសមត្ថភាពបច្ចុប្បន្ន។

**ច្រកវាយតម្លៃ៖** ច្រកអាចបត់បែនបានដែលបង្កលក្ខណៈងាយស្រួលដល់អ្នកសិក្សា ឬអ្នកកំពុងធ្វើការក្នុងការចាប់យកកម្រិតគុណវុឌ្ឍិជាក់លាក់ ឬកម្រិតគុណវុឌ្ឍិខ្ពស់បន្ថែមទៀត តាមរយៈការទទួលស្គាល់ការសិក្សាពីមុន រួមមាន ការផ្ទេរក្រេឌីត ព្រមទាំងការទទួលស្គាល់បទពិសោធន៍ និងសមត្ថភាពបច្ចុប្បន្ន។

**មជ្ឈមណ្ឌលវាយតម្លៃ៖** ជាស្ថាប័នដែលត្រូវបានទទួលស្គាល់ និងចុះបញ្ជីការដោយក្រសួងទេសចរណ៍សម្រាប់អនុវត្តដំណើរការ និងនីតិវិធីនានានៃការវាយតម្លៃលើគុណវុឌ្ឍិអ្នកជំនាញទេសចរណ៍។

## ជំពូកទី២
## សមត្ថកិច្ចក្នុងការគ្រប់គ្រង និងពង្រឹងគុណភាពបណ្តុះបណ្តាល

**ប្រការ៥.-**

ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍មានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងដឹកនាំការអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN MRA-TP)។

ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍មានសមត្ថកិច្ចក្នុងការផ្តល់វិញ្ញាបនបត្រទទួលស្គាល់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន ឬលុបចោលការទទួលស្គាល់ ក្នុងករណីស្ថាប័នមិនគោរពតាមបទប្បញ្ញត្តិ និងលក្ខណៈវិនិច្ឆ័យ ដែលកំណត់ដោយក្រសួងទេសចរណ៍។

**ប្រការ៦.-**

ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ានត្រូវធ្វើការស្នើសុំទទួលស្គាល់កម្មវិធីសិក្សា និងការបណ្តុះបណ្តាលរបស់ខ្លួនមកក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍មុនធ្វើការបណ្តុះបណ្តាល និងវាយតម្លៃ។

**ប្រការ៧.-**

ដើម្បីពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន គ្រប់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ទាំងអស់ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវចុះបញ្ជីការ ឬសុំបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ស្របតាមបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍។
- ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីផ្សេងៗ តាមការអញ្ជើញរបស់ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។
- ត្រូវសហការផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ នៃការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN MRA-TP) ដល់ភាគីពាក់ព័ន្ធនៅតាមតំបន់របស់ខ្លួន។
- ត្រូវពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍របស់ខ្លួន ដោយត្រូវរៀបចំផែនការសកម្មភាពច្បាស់លាស់ អនុវត្តបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។
- អនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន ដោយសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។
- អនុវត្តយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ានដែលដាក់ឱ្យប្រើប្រាស់ដោយក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។
- ត្រូវមានគ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលដែលមានសមត្ថភាព និងទទួលស្គាល់ដោយក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ស្របតាមយន្តការអាស៊ាន។
- អនុវត្ត និងប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ និងត្រូវចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន ក្នុងប្រព័ន្ធចុះបញ្ជីជាតិ និងអាស៊ាន។
- ត្រូវមានឯកសារបណ្តុះបណ្តាល (Training Toolboxes) សម្រាប់ពិគ្រោះយោបល់ និងការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងភាគីពាក់ព័ន្ធ តម្កល់ទុកនៅបណ្ណាល័យរបស់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍។
- ត្រូវសហការ និងអនុវត្តយន្តការផ្សេងៗទៀតស្តីពីការធានាគុណភាពអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលកំណត់ដោយក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។

**ប្រការ៨.-**

គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍នឹងចុះត្រួតពិនិត្យតាមដានការបណ្ដុះបណ្ដាលរបស់ស្ថាប័នបណ្ដុះបណ្ដាលវិជ្ជាជីវៈទេសចរណ៍ជាប្រចាំតាមការចាំបាច់។

## ជំពូកទី៣
## ការវាយតម្លៃគុណវុឌ្ឍិអ្នកជំនាញទេសចរណ៍

**ប្រការ៩.-**

រាល់ការវាយតម្លៃត្រូវស្របតាមគោលការណ៍វាយតម្លៃផ្អែកលើសមត្ថភាព (Competency-Based Assessment) ដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន និងយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។ ការវាយតម្លៃទទួលស្គាល់អាចត្រូវធ្វើឡើងជា ០២(ពីរ) ទម្រង់ គឺការវាយតម្លៃទទួលស្គាល់សមត្ថភាព(Competencies Assessment) និងការវាយតម្លៃទទួលស្គាល់កម្រិតគុណវុឌ្ឍិ (Qualification Assessment)។

**ប្រការ១០.-**

ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការវាយតម្លៃអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន មជ្ឈមណ្ឌលវាយតម្លៃត្រូវធ្វើការស្នើសុំមកក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ដើម្បីសុំការទទួលស្គាល់ និងចុះបញ្ជិកាដោយគោរពតាមនីតិវិធីផ្សេងៗ ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ១១.-**

ការវាយតម្លៃត្រូវរៀបចំឡើងដោយអ្នកវាយតម្លៃ (Assessors) ដែលមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តយន្តការវាយតម្លៃ ផ្អែកលើសមត្ថភាព។

**ប្រការ១២.-**

រាល់ការវាយតម្លៃត្រូវគោរពតាមគោលការណ៍គ្រឹះក្នុងការវាយតម្លៃ (Principles of Assessment) រីឯការវិនិច្ឆ័យភស្តុតាងដែលប្រមូលបានត្រូវគោរពទៅតាមបទដ្ឋាននៃការវាយតម្លៃ (Rules of Evidence)។

## ជំពូកទី៤
## យន្តការគ្រប់គ្រងការបណ្ដុះបណ្ដាល និងវាយតម្លៃគុណវុឌ្ឍិអ្នកជំនាញទេសចរណ៍

**ប្រការ១៣.-**

ស្ថាប័នបណ្ដុះបណ្ដាលវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃអ្នកជំនាញទេសចរណ៍ត្រូវធ្វើរបាយការណ៍ស្ដីពីការបណ្ដុះបណ្ដាល និងវាយតម្លៃរបស់ខ្លួនមកលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍រៀងរាល់ត្រីមាស ឬតាមការស្នើសុំ។

**ប្រការ១៤.-**

លេខាធិការដ្ឋានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ត្រូវរៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំ និងធ្វើបច្ចុប្បន្នភាពស្តង់ដាកម្មវិធីបណ្តុះបណ្តាល ស្តង់ដាសមត្ថភាព ឯកសារបណ្តុះបណ្តាល និងកែសម្រួលបទដ្ឋានគតិយុត្ត ឬយន្តការទ្រទ្រង់នានាដែលបម្រើដល់ការអប់រំបណ្តុះបណ្តាល និងវាយតម្លៃអ្នកជំនាញទេសចរណ៍នៅកម្ពុជាស្របតាមនិន្នាការ និងសេចក្តីត្រូវការជាក់ស្តែង។

**ប្រការ១៥.-**

រាល់ការទទួលស្គាល់គុណវុឌ្ឍិវិញ្ញាបនបត្រ ឬសញ្ញាបត្រវិជ្ជាជីវៈត្រូវផ្តល់ដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍តាមគំរូវិញ្ញាបនបត្រ ឬសញ្ញាបត្រវិជ្ជាជីវៈ ដូចមានក្នុងឯកសារស្តីពីយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន។

**ប្រការ១៦.-**

គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍នឹងត្រូវកត់ត្រាចូលក្នុងសៀវភៅជំនាញទេសចរណ៍ និងប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ១៧.-**

យន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ានអាចត្រូវបានធ្វើបច្ចុប្បន្នភាពដោយគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ក្នុងករណីចាំបាច់។ សេចក្តីជូនដំណឹងបន្ថែមអំពីការកែសម្រួលខាងលើនឹងត្រូវចេញដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍ដែលជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។

**ប្រការ១៨.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៩.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកវិទ្យាស្ថានជាតិទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

ប្រធានមន្ទីរទេសចរណ៍ រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
- ដូចប្រការ ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ